ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

រឿងព្រហ្មទណ្ឌ

លេខ០១/០៥-០១-២០០៤

សាលដីកាលេខ៦៩«ង»

ចុះថ្ងៃទី០១-៧-២០០៨

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រចុះថ្ងៃទី០៩-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍កាលពីថ្ងៃទី០១-៧-២០០៨ដែលមានសមាសភាពដូចតទៅ៖

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជំរះ</u>**

**លោក** [redacted] **ប្រធាន**

**លោកស្រី** [redacted] **ចៅក្រមប្រឹក្សា**

**លោក** [redacted] **ចៅក្រមប្រឹក្សា**

**តំណាងមហាអយ្យការ**

**លោក** [redacted]

**ក្រឡាបញ្ជី**

**លោកស្រី** [redacted]

**១-ជនជាប់ចោទឈ្មោះ** [redacted] **សារ៉ាត (ចុះបណ្ដឹងឧទ្ធរណ៍)**ភេទប្រុស អាយុ២៣ឆ្នាំ មុខរបរដាំឈូក ជាតិខ្មែរ កើតនៅភូមិឆាយរំព័ទ្ធ ឃុំកន្ទើរ ស្រុកសង្កែ ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃផ្ទះសង់ថ្មី ផ្លូវលំ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ)នៅលីវ។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី០១-៨-២០០២។

**២-ជនជាប់ចោទឈ្មោះ** [redacted] **គឿន(ចុះបណ្ដឹងឧទ្ធរណ៍)**ភេទប្រុស អាយុ២៨ឆ្នាំ មុខរបរធ្វើស្រែ ជាតិខ្មែរ កើតនៅភូមិតាង៉ក ឃុំរំចេក ស្រុកព្រះស្ដេច ខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃផ្ទះជួលក្បែរសណ្ឋាគារ [redacted] ឪពុកឈ្មោះ [redacted] ហាន (ស)ម្ដាយឈ្មោះ [redacted] ឌិន (រ)ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ។ទោសពីមុនគ្មាន។ឃុំ





Scanned with CamScanner

ខ្លួនថ្ងៃទី០១-៨-២០០២។

**៣-ជនជាប់ចោទឈ្មោះ** [redacted] **ប៊ុនធឿន(ចុចបណ្ដឹងឧទ្ធរណ៍)**ភេទប្រុស អាយុ២៣ឆ្នាំ មុខរបរកម្មករសំណង់ ជាតិខ្មែរ កើតនៅភូមិទូល ឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង ទីលំនៅសព្វថ្ងៃផ្ទះជួល [redacted] ឪពុកឈ្មោះ: [redacted] (ស)ម្ដាយឈ្មោះ: [redacted] (រ)នៅលីវ។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី០១-៨-២០០២។

**៤-ជនជាប់ចោទឈ្មោះ** [redacted] **គាន់(ចុចបណ្ដឹងឧទ្ធរណ៍)**ភេទប្រុស អាយុ១៨ឆ្នាំ មុខរបរកម្មករ ជាតិខ្មែរ កើតនៅភូមិបាគ្រៀច ឃុំព្រៃឈរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃស្នាក់នៅ [redacted] ឪពុកឈ្មោះ: [redacted] (ស)ម្ដាយឈ្មោះ: [redacted] (រ)នៅលីវ។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី០១-៨-២០០២។

**៥-ជនជាប់ចោទឈ្មោះ** [redacted] **សុខឃាន ហៅ ខ្មៀន(ចុចបណ្ដឹងឧទ្ធរណ៍)**ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិពាមរក៏ ឃុំពាមរក៏ ស្រុកពាមជរ ខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃផ្ទះជួលក្រោយ [redacted] ឪពុកឈ្មោះ: [redacted] អួន (រ)ម្ដាយឈ្មោះ:ជូ យឹង (រ)នៅលីវ។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី០១-៨-២០០២។

**៦-ជនជាប់ចោទឈ្មោះ** [redacted] **ឈាងលី (ចុចបណ្ដឹងឧទ្ធរណ៍)**ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរកងរាជអាវុធហត្ថ កើតនៅភូមិពោធិស្នៀង ឃុំសណ្ដែក ស្រុកបាធាយ ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃស្នាក់នៅក្នុង [redacted] ឪពុកឈ្មោះ: [redacted] (រ)ម្ដាយ ឈ្មោះ: [redacted] (រ)ប្រពន្ធឈ្មោះ: [redacted] មានកូន១នាក់។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី០១-៨-២០០២។

ត្រូវចោទពីបទ ប្លន់ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២២.២៤ ខែ៧ ឆ្នាំ២០០២ , ថ្ងៃទី២២ ខែ៥ ឆ្នាំ២០០២ តាមមាត្រា៦ នៃច្បាប់ស្ដីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

**៧-ជនជាប់ចោទឈ្មោះ** [redacted] **ធី (ចុចបណ្ដឹងឧទ្ធរណ៍)**ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ កើតនៅ និង ទីលំនៅសព្វថ្ងៃ [redacted] សព្វថ្ងៃ ឪពុកឈ្មោះ: [redacted] (ស)ម្ដាយឈ្មោះ: [redacted] (ស)។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី០១-៨-២០០២។

**៨-ជនជាប់ចោទឈ្មោះ** [redacted] **វណ្ណារិន (ចុចបណ្ដឹងឧទ្ធរណ៍)**ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់លេខ១ ក្រុងភ្នំពេញ ទីលំនៅសព្វថ្ងៃផ្ទះ: [redacted] ឪពុកឈ្មោះ: [redacted] (រ)ម្ដាយឈ្មោះ: [redacted] (រ) ប្រពន្ធឈ្មោះ:យុគ ស៊ីថា មានកូន៥នាក់។ទោសពីមុនគ្មាន។ឃុំខ្លួនថ្ងៃទី០១-៨-២០០២។

ត្រូវចោទពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២២.២៤ ខែ៧ ឆ្នាំ២០០២ ,ថ្ងៃទី២២ ខែ៥ ឆ្នាំ២០០២ តាមមាត្រា៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

បានឃើញពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២២-១០-២០០៣របស់ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ មិនសុខចិត្តត្រង់ចំណុចទី៣នៃសេចក្ដីសំរេច ។



Scanned with CamScanner

**៦ដំណើររឿងមានដូចតទៅ៖**

តាមរបាយការណ៍សំយោគលេខ១៦៣/០២ចុះថ្ងៃទី៣០-៧-២០០២របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតស្រាលស្តីពីករណីប្លន់ម៉ូតូ ថាមានជនល្មើសឈ្មោះសោម ប៊ុនធឿន និងបក្សពួក៣នាក់ទៀត គឺឈ្មោះរាលី,ជាត់ សាក់ត់ និង នាង កៀន បានធ្វើសកម្មភាពប្លន់២លើក លើកទី១នៅថ្ងៃទី២៤-៧-២០០២ប្លន់ម៉ូតូC១០០ ពណ៌ក្រហម ដោយប្រើកាំភ្លើងK៥៩ភ្ជង់យក។លើកទី២ប្លន់បានម៉ូតូម៉ាកប្រេះពណ៌កាប់ស្គាំង មានគូកន២នាក់គឺអាខ្មៅ និង រាលី ដោយប្រើកាំភ្លើងK៥៩ភ្ជង់យក។ជនល្មើសឈ្មោះ[redacted]កៀន ហៅស្រអែម និង បក្សពួក៥នាក់ គឺឈ្មោះ[redacted]សុខយេន,ធី, [redacted]ប៊ុនធឿន ហៅ បាន និង [redacted]សាក់ត់ បានប្លន់នៅចំណុចចំណុចមន្ទីរពេទ្យកុមារមេជ្ឈិម គឺប្រើ K៥៩។ជនល្មើស[redacted] កាន់ សារភាពថាខ្លួនធ្លាប់ប្លន់៣លើក លើកទី១ថ្ងៃទី២២-៧-២០០២ប្លន់បានម៉ូតូ ប្លន់បានម៉ូតូគុប៥០មានគូកនអាខ្មៅ និង [redacted]ប៊ុនធឿន លើកទី២នៅថ្ងៃទី២៤-៧-២០០២ប្លន់ម៉ូតូ C១០០កូរ៉េ ដោយប្រើកាំភ្លើង K៥៩។ ជនល្មើស[redacted] សុវណ្ណារិទ្ធសារភាពថាធ្លាប់បានទិញម៉ូតូពីឈ្មោះ[redacted] សាក់ត់ចំនួន២លើក។ជនល្មើសឈ្មោះ[redacted] ធី សារភាពថាធ្លាប់បានទិញម៉ូតូពីឈ្មោះ[redacted] សុវណ្ណារិទ្ធចំនួន៦លើកហើយត្រូវសមត្ថកិច្ចចាប់ខ្លួនបានតែម្តង។

បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៥២«ច»/២៧-៨-២០០៣របស់តុលាការក្រុងភ្នំពេញសំរេចសេចក្តីដូចតទៅ៖

១-ផ្តន្ទាទោសលើឈ្មោះ៖

-[redacted]សាក់ត់ ភេទប្រុស អាយុ២៣ឆ្នាំ.

-[redacted]ប៊ុនធឿន ភេទប្រុស អាយុ២៣ឆ្នាំ.

-[redacted]សុខយេន ភេទប្រុស អាយុ១៩ឆ្នាំ.

ដាក់ពន្ធនាគារកំណត់ម្នាក់ៗរយៈពេល៦ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០១-៨-២០០២ ពីបទប្លន់ប្រដាប់អាវុធ ប្រព្រឹត្តនៅទីក្រុងភ្នំពេញថ្ងៃទី២៤-៧-២០០២ និង ២០០២តាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

២-ផ្តន្ទាទោសលើឈ្មោះ៖

-[redacted]កាន់ ភេទប្រុស អាយុ២៣ឆ្នាំ.

-[redacted]កៀន ភេទប្រុស អាយុ២៨ឆ្នាំ.

ដាក់ពន្ធនាគារកំណត់ម្នាក់ៗរយៈពេល៥ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០១-៨-២០០២ ពីបទប្លន់ប្រដាប់អាវុធ ប្រព្រឹត្តនៅទីក្រុងភ្នំពេញថ្ងៃទី២៤-៧-២០០២ និង ២០០២តាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

៣-លើកលែងចោទប្រកាន់លើឈ្មោះ៖

-[redacted]សាក់ត់ ភេទប្រុស អាយុ២៣ឆ្នាំ.

-[redacted]ប៊ុនធឿន ភេទប្រុស អាយុ២៣ឆ្នាំ.

-[redacted]សុខយេន ភេទប្រុស អាយុ១៩ឆ្នាំ.

-[redacted]កាន់ ភេទប្រុស អាយុ១៨ឆ្នាំ.



Scanned with CamScanner

-[redacted] ភៀន ភេទប្រុស អាយុ២៨ឆ្នាំ.

ពីបទប្លន់ប្រដាប់អាវុធ ប្រព្រឹត្តនៅទីក្រុងភ្នំពេញថ្ងៃទី២២-៥-២០០២ និង០៩-៧- ២០០២ និង ២២-៧-២០០២ តាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

-គឹម ឈាងលី ភេទប្រុស អាយុ២៩ឆ្នាំ ពីបទប្លន់ប្រដាប់អាវុធ ប្រព្រឹត្តនៅទីក្រុងភ្នំពេញ ថ្ងៃទី២២-៥-២០០២ ,០៩-៧-២០០២ ,២២-៧-២០០២ និង ២៩-៧-២០០២ និង ឆ្នាំ២០០២។

៤-ផ្តន្ទាទោសលើឈ្មោះ:

-[redacted] ធី ភេទប្រុស អាយុ៣០ឆ្នាំ.

-[redacted] ណ្ណារិន ភេទប្រុស អាយុ៣៥ឆ្នាំ.

ដាក់ពន្ធនាគារកំណត់ម្នាក់ៗរយៈពេល១ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០១-៨-២០០២ តែទោសនេះត្រូវព្យួរទាំងស្រុង ក្នុងកំរិតសាកល្បងរយៈពេល៥ឆ្នាំ ពីបទទទួលផលចោរកម្ម ប្រព្រឹត្តនៅទីក្រុងភ្នំពេញកាលពីថ្ងៃទី២២ និង ថ្ងៃទី២៨ ខែមករា ឆ្នាំ២០០២ និង ក្នុងអំឡុងឆ្នាំ ២០០២។

៥-ទុកសិទ្ធិឲ្យជនរងគ្រោះ ប្តឹងទាស់ំណងនាពេលក្រោយបាន។

៦-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះជនជាប់ចោទ កំបាំងមុខជនរងគ្រោះ សំរេចបើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២-១០-២០០៣របស់ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ មិនសុខចិត្តត្រង់ចំណុចទី៣នៃសេចក្តីសំរេច ។

បានឃើញរបាយការណ៍របស់សាលាឧទ្ធណ៍។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

<u>នាពេលសវនាការ</u>

ចៅក្រមអានរបាយការណ៍របស់សាលាឧទ្ធរណ៍.

ក្រឡាបញ្ជីអានចំលើយជនជាប់ចោទឈ្មោះ [redacted] សារ៉ាត់.

ក្រឡាបញ្ជីអានចំលើយជនជាប់ចោទឈ្មោះ [redacted] ប៊ុនធឿន.

ក្រឡាបញ្ជីអានចំលើយជនជាប់ចោទឈ្មោះ [redacted] សុខយេន.

ក្រឡាបញ្ជីអានចំលើយជនជាប់ចោទឈ្មោះ [redacted] ភាន់.

ក្រឡាបញ្ជីអានចំលើយជនជាប់ចោទឈ្មោះ [redacted] ភៀន.

ក្រឡាបញ្ជីអានចំលើយជនជាប់ចោទឈ្មោះ [redacted] ឈាងលី.

ក្រឡាបញ្ជីអានចំលើយជនរងគ្រោះឈ្មោះ [redacted] កែវមុន្នី.

មេធាវី [redacted] ធីតា សន្និដ្ឋានថាៈខ្លួនជាមេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ឈាងលី ។ នៅក្នុងសាលក្រមព្រហ្មទណ្ឌលេខ៥២«ចៅ»/២៧.៨.២០០៣របស់តុលាការក្រុងភ្នំពេញបានសំរេចលើកលែងចោទប្រកាន់លើកូនក្តីខ្លួនឈ្មោះគឹម ឈាងលី រួចហើយ។តាមរបាយការណ៍របស់ប៉ូលីស កូនក្តីខ្លួនឈ្មោះគឹម ឈាងលី ពុំមានពាក់ព័ន្ធក្នុងសំណុំរឿងប្លន់ទាំងអស់នេះទេ។ សំណូមពរសុំតំកល់សាលក្រមព្រហ្មទណ្ឌលេខ៥២«ចៅ»/២៧.៨.២០០៣របស់តុលាការក្រុងភ្នំពេញទុកជាបានការដដែល។



Scanned with CamScanner

តំណាងមហាអយ្យការសន្និដ្ឋានថា៖សាលក្រមព្រហ្មទណ្ឌរបស់តុលាការក្រុងភ្នំពេញលេខ៥២-ច-/២៧.៨.២០០៣សំរេចមានភាពត្រឹមត្រូវហើយ លើកលែងតែចំណុចទី៣នៃសេចក្តីសំរេច ។សំណូមពរសុំក្រុមប្រឹក្សាសំរេចចោទប្រកាន់លើជនជាប់ចោទទាំង៦នាក់ ដែលមានឈ្មោះ[redacted] សារ៉ាត់,ឈ្មោះ[redacted] ប៊ុនធឿន,ឈ្មោះ[redacted] សុខយេន,ឈ្មោះ[redacted] ភាន់ និងឈ្មោះ[redacted]កៀន ពីបទប្លន់ ប្រព្រឹត្តនៅទីក្រុងភ្នំពេញ។

**<u>សាលាឧទ្ធរណ៍</u>**

យល់ឃើញថាបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២២-១០-២០០៣របស់ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ ដែលបានប្តឹងឧទ្ធរណ៍មិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៥២-ច-/២៧.៨.២០០៣របស់តុលាការក្រុងភ្នំពេញត្រង់ចំណុចទី៣នៃសេចក្តីសំរេច ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា១៧៨នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន។

យល់ឃើញថាតាមដីកាសន្និដ្ឋានស្ថាពរលេខ២០០២/១១-៧-២០០៣របស់ព្រះរាជអាជ្ញារងអមតុលាការក្រុងភ្នំពេញ បានសំរេចចោទប្រកាន់លើឈ្មោះ៖

១.[redacted]ប៊ុនធឿន ពីបទប្លន់ ប្រព្រឹត្តកាលពីថ្ងៃទី២២.៥.២០០២.ថ្ងៃទី២២.៧.២០០២.ថ្ងៃទី២៤.៧.២០០២ និង ឆ្នាំ២០០២.

២.នាង [redacted] ពីបទប្លន់ ប្រព្រឹត្តកាលពីថ្ងៃទី២២.៥.២០០២.ថ្ងៃទី០៩.៧.២០០២.ថ្ងៃទី២៤.៧.២០០២ និង ឆ្នាំ២០០២.

៣.[redacted] សារ៉ាត់ ពីបទប្លន់ ប្រព្រឹត្តកាលពីថ្ងៃទី២២.៥.២០០២.ថ្ងៃទី២២.៧.២០០២.ថ្ងៃទី២៤.៧.២០០២ និង ឆ្នាំ២០០២.

៤.[redacted] ឈាងលី ពីបទប្លន់ ប្រព្រឹត្តកាលពីថ្ងៃទី២២.៥.២០០២.ថ្ងៃទី០៩.៧.២០០២.ថ្ងៃទី២២.៧.២០០២.ថ្ងៃទី២៤.៧.២០០២ និង ឆ្នាំ២០០២.

៥.[redacted] ភាន់ ពីបទប្លន់ ប្រដាប់អាវុធ ប្រព្រឹត្តកាលពីថ្ងៃទី២២.៧.២០០២.ថ្ងៃទី២៤.៧.២០០២. និង ឆ្នាំ២០០២.

៦.[redacted] សុខយេន ពីបទប្លន់ ប្រដាប់អាវុធ ប្រព្រឹត្តកាលពីថ្ងៃទី២៤.៧.២០០២ និង ឆ្នាំ២០០២.

នៅទីក្រុងភ្នំពេញ តាមមាត្រា៦ច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

យល់ឃើញថា ជនជាប់ចោទឈ្មោះ[redacted] ប៊ុនធឿន.[redacted] កៀន[redacted] សារ៉ាត់.[redacted] ភាន់.[redacted] សុខយេន.បានទទួលស្គាល់នាពេលសវនាការសាលាឧទ្ធរណ៍កាលពីថ្ងៃទី១៧.៧.២០០៧ ថាបានប្រព្រឹត្តអំពើប្លន់តែម្តងទេនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី២៤.៧.២០០២ ដោយឡែកបទចោទប្រកាន់ផ្សេងទៀត សុំបដិសេធ។ចំណែកឈ្មោះ[redacted]ឈាងលី បានបដិសេធរាល់ការចោទប្រកាន់ស្ថាពររបស់ព្រះរាជអាជ្ញា ដោយសំអាងហេតុថា ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់នេះទេ ហើយក៏ពុំដែលស្គាល់ជនជាប់ចោទទាំង៥ខាងលើនេះទេ។

យល់ឃើញថា តាមរបាយការណ៍លេខ១៦៣/០៨.១០.២០០៧ដែលបានឆ្លើយតបទៅនឹងសាលដីការបៀបលេខ០៤ង/១៧.៧.២០០៧បញ្ជាក់ថា ពុំមានករណីប្លន់ក្នុងសង្កាត់ទឹកថ្លា





Scanned with CamScanner

៤ ចំពោះប៉ុស្តិ៍នគរបាលរដ្ឋបាលស្រះចកក អះអាងថាពុំមានជនរងគ្រោះដាក់ពាក្យប្ដឹងទេ។

យល់ឃើញថា តាមចំលើយរបស់ជនជាប់ចោទទាំង៦នាក់នេះនៅប៉ុស្តិ៍ប៉ូលីសបាន ឆ្លើយបញ្ជាក់ថា ប្លន់ជាច្រើនលើក ដូចមានចំលើយឈ្មោះ[redacted] សុខយេនចុះថ្ងៃទី២៥.៧.២០០២.ចំលើយឈ្មោះមាស ភាន់ចុះថ្ងៃទី២៥.៧.២០០២.ចំលើយរបស់ឈ្មោះ[redacted] សារ៉ាត់ចុះថ្ងៃទី២៧.៥.២០០២.ចំលើយ[redacted] ប៊ុនធឿនចុះថ្ងៃទី២៥.៧.២០០២.ចំលើយឈ្មោះ[redacted] គឿន ចុះថ្ងៃទី២៧.៧.២០០០២.ចំលើយឈ្មោះ[redacted]ឈងលីចុះថ្ងៃទី៣០.៧.២០០២ ហើយតាម បណ្ដឹងចុះថ្ងៃទី២៥.៥.២០០២របស់ឈ្មោះ[redacted] មុន្នី ជាជនរងគ្រោះក្នុងអំពើប្លន់កាលពីថ្ងៃទី ២២.៥.២០០២.របាយការណ៍របស់នគរបាលមណ្ឌលទី៧ ផ្ញើជូនប្រធានប៉ុស្តិ៍នគរបាលចុះថ្ងៃទី ២៧.៧.២០០៧មានករណីប្លន់ ប្រព្រឹត្តកាលពីថ្ងៃទី២២.៧.២០០២ កំណត់ហេតុបណ្ដឹងចុះថ្ងៃទី ០៩.៧.២០០២របស់ឈ្មោះ[redacted] ចិន្តា ដែលជាជនរងគ្រោះប្ដឹងពាក់ព័ន្ធទៅនឹងករណីប្លន់កាលពី ថ្ងៃទី០៩.៧.២០០២។ឃើញថាចំលើយរបស់ជនជាប់ចោទ និង ជនរងគ្រោះមានទំនាក់ទំនង នឹងគ្នា។ដូចនេះការចោទប្រកាន់ស្ថាពររបស់ព្រះរាជអាជ្ញាមានភាពត្រឹមត្រូវ។

យល់ឃើញថាសាលក្រមព្រហ្មទណ្ឌលេខ៥៥២«ច»/២៧-៨-២០០៣របស់តុលាការក្រុង ភ្នំពេញ ក្នុងចំណុចទី៣នៃសេចក្ដីសំរេចពុំមានភាពត្រឹមត្រូវតាមអង្គហេតុ និង គតិច្បាប់ទេ។ សាលាឧទ្ធរណ៍គប្បីបដិសេធសាលក្រមនេះ ត្រង់ចំណុចទី៣ចោល និង សំរេចជាថ្មី ដោយ ផ្អែកតាមការយល់ឃើញខាងលើ។

## ហេតុដូច្នេះ ទនិច្ឆ័យសេចក្ត

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២២-១០-២០០៣របស់ព្រះរាជអាជ្ញារងអម តុលាការក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ៥៥២«ច»/២៧-៨-២០០៣របស់តុលាការក្រុង ភ្នំពេញទុកជាបានការ វៀរលែងតែចំណុចទី៣នៃសាលក្រម ត្រូវបដិសេធចោល និង សំរេចជា ថ្មីទៅជា៖

ក/ផ្ដន្ទាទោសលើឈ្មោះ៖

-[redacted]សារ៉ាត់ ភេទប្រុស អាយុ២៣ឆ្នាំ.

-[redacted] ប៊ុនធឿន ភេទប្រុស អាយុ២៣ឆ្នាំ.

-[redacted] សុខយេន ភេទប្រុស អាយុ១៩ឆ្នាំ.

-[redacted] គឿន ភេទប្រុស អាយុ២៣ឆ្នាំ.

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល៥ឆ្នាំ(ប្រាំឆ្នាំ) បន្ថែមលើទណ្ឌកម្មដែលបាន សំរេចក្នុងចំណុចទី១ និង ទី២នៃសាលក្រមព្រហ្មទណ្ឌលេខ៥៥២«ច»/២៧-៨-២០០៣ ពីបទប្លន់ប្រដាប់អាវុធ ប្រព្រឹត្តកាលពីថ្ងៃទី២២-៥-២០០២,ថ្ងៃទី០៩-៧-២០០២ និង ថ្ងៃទី២២-៧-២០០២នៅទីក្រុងភ្នំពេញ តាមមាត្រា៦នៃច្បាប់ស្ដីពីស្ថានទំងន់ទោសនៃ បទឧក្រិដ្ឋ។

ខ/ផ្ដន្ទាទោសលើឈ្មោះ[redacted] ឈាងលី ដាក់ពន្ធនាគារកំណត់១០ឆ្នាំ(ដប់ឆ្នាំ) ពីបទប្លន់ ប្រដាប់អាវុធ ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី២២-៥-២០០២ ថ្ងៃទី០៩-៧-២០០២

ថ្ងៃទី២២-៧-២០០២ ថ្ងៃទី២៤-៧-២០០២ ដល់ឆ្នាំ២០០២ តាមមាត្រា៦នៃច្បាប់ស្ដីពីស្ថានទំងន់នៃបទឧក្រិដ្ឋ។

ចំណុចផ្សេងពីនេះនៃសាលក្រមរក្សាទុកជាបានការដដែល។

៣-សាលដីកានេះជំនុំជំរះជាសាធារណៈកាលពីថ្ងៃទី២៣-៦-២០០៨ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារ៉ាត់, [redacted] ប៊ុនធឿន, [redacted] សុខឃេន, [redacted] ភាន់, [redacted] គៀន, [redacted] ឈាងលី ចំពោះមុខ មេធាវី [redacted] ធីតា, [redacted] សូនី និង ប្រកាសជាសាធារណៈនៅថ្ងៃទី០១-៧-២០០៨ កំបាំងមុខជនជាប់ចោទ មេធាវីការពាជនជាប់ចោទ។

បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់។

**សាលដីកានេះចូលស្ថាពរតែចំពោះឈ្មោះ [redacted] សារ៉ាត់.**

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកំលាំងប្រដាប់អាវុធគ្រប់ដំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសំរេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

---

បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍,ថ្ងៃទី 10 ខែ 3 ឆ្នាំ២០១៤

| **បានឃើញ** | |
|---|---|
| **ប្រធានសាលាឧទ្ធរណ៍** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |



Scanned with CamScanner